ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**
-សំណុំរឿងរដ្ឋប្បវេណីលេខៈ ២៨៧
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០
-សាលក្រមរដ្ឋប្បវេណីលេខៈ ១១ "ជ"
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

# សាលក្រម

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ២៨៧ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

-ដើមចោទឈ្មោះ [redacted] សម្ផស្ស ភេទស្រី កើតឆ្នាំ១៩៨៣ មានទីលំនៅភូមិ[redacted] ដោយមានលោកមេធាវី [redacted] មានអត្តលេខៈ [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-ចុងចម្លើយឈ្មោះ [redacted] វណ្ណា ភេទស្រី កើតឆ្នាំ១៩៦១ មុខរបរកុងស៊ីសត្វឃាត (កន្លែងធ្វើជ្រូក) មានទីលំនៅ[redacted] ដោយមានលោកមេធាវី [redacted] មានអត្តលេខៈ ២៩៩ និងលោកមេធាវី [redacted] មានអត្តលេខៈ [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ និងចំណុចវិវាទ**

ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញៈ សុំឱ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោមៈ

-សុំទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា ធ្វើការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ (ដី) ដែលមានក្បាលដីលេខៈ ៥៨៥ មានទំហំ ៨៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ឱ្យមកដើមចោទឈ្មោះ [redacted] សម្ផស្ស។

ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សម្ផស្ស បានដាក់ពាក្យបណ្តឹងចូលមកសាលាដំបូងខេត្តតាកែវ ដោយប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា ធ្វើការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ (ដី) ដែលមានក្បាលដីលេខៈ ៥៨៥ មានទំហំ ៨៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ឱ្យមក



Scanned with CamScanner

ដើមចោទឈ្មោះ [redacted] សម្ផស្ស វិញ។ ដោយហេតុថាកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ចុងចម្លើយឈ្មោះ [redacted] វណ្ណា បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខៈ ៣៤៨ ប.ផ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ នៃដីមួយកន្លែងដែលមានក្បាលដីលេខៈ ៥៨៥ មានទំហំ ៨៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ឱ្យមកដើមចោទ ដោយមានការផ្តិតស្នាមមេដៃរបស់អ្នកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិ ព្រមទាំងមានស្នាមមេដៃរបស់សាក្សី និងមានការចុះហត្ថលេខាដឹងឮពីអាជ្ញាធរភូមិឃុំត្រឹមត្រូវផងដែរ។ ក្រោយពេលដែលចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីនៃដីខាងលើឱ្យទៅដើមចោទរួចហើយ គឺដើមចោទ និងចុងចម្លើយពុំបាននាំគ្នាទៅបំពេញនីតិវិធីផ្ទេរកម្មសិទ្ធិ (ប្លង់រឹង) នៅចំពោះមុខមន្ត្រីសុរិយោដីនោះទេ ហើយចំពោះអចលនវត្ថុខាងលើដើមចោទក៏បានកាន់កាប់ ប្រើប្រាស់អាស្រ័យផលរហូតមកដល់បច្ចុប្បន្នផងដែរ។ ទើបតែនៅក្នុងអំឡុងចុងឆ្នាំ ២០១៨ ចុងចម្លើយក៏មានទំនាស់ជាមួយនឹងដើមចោទអំពីបញ្ហាគ្រួសារ រួចហើយចុងចម្លើយក៏បានធ្វើលិខិតស្នើសុំទប់ស្កាត់រក្សាការពារលេខៈ ១០៨៦ បជ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ដោយជម្រាបទៅអាជ្ញាធរភូមិឃុំដើម្បីសុំឱ្យភូមិឃុំជួយទប់ស្កាត់ដើមចោទមិនឱ្យធ្វើការលក់ ការដោះដូរ ដាក់បញ្ចាំ ដាក់ធានា បង្កើតហ៊ីប៉ូតែក ធ្វើអំណោយ ឬផ្ទេរសិទ្ធិអចលនវត្ថុខាងលើក្នុងគោលបំណងដកហូតយកដីខាងលើនេះពីដើមចោទមកវិញ ដោយចុងចម្លើយបានអះអាងថាដីខាងលើជាដីរបស់ខ្លួន ពុំមែនជាដីមរតករបស់ម្តាយឈ្មោះ [redacted] រ៉ន នោះទេ ចំណែកឯចុងចម្លើក៏បានអះអាងថាអចលនវត្ថុខាងលើនេះ គឺជាប្រភពដីមរតករបស់ជីដូនខ្លួនឈ្មោះ [redacted] រ៉ន ដែលបានរក្សាទុកឱ្យមកខ្លួនដែលជាដើមចោទ ដោយពុំមែនជាទ្រព្យសម្បត្តិរបស់ចុងចម្លើយនោះទេ។ ហើយដើមចោទក៏ពុំយល់ព្រមប្រគល់អចលនវត្ថុខាងលើនេះឱ្យទៅចុងចម្លើយវិញនោះដែរ។ ចំពោះរឿងហេតុទាំងអស់នេះហើយទើបដើមចោទសម្រេចចិត្តដាក់ពាក្យប្តឹងចូលមកសាលាដំបូងខេត្តតាកែវដើម្បីស្នើសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា ធ្វើការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដូចដែលមានក្នុងកម្មវត្ថុនៃពាក្យបណ្តឹងខាងលើនេះឱ្យមកខ្លួនជាម្ចាស់កម្មសិទ្ធិ។

**គ. ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**គ.១. ចំណុចវិវាទ :**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២កន្លងមក តុលាការកំណត់បានចំណុចវិវាទនៃរឿងក្តីមានដូចតទៅ:

-តើចុងចម្លើយមានមូលហេតុត្រឹមត្រូវតាមផ្លូវច្បាប់ក្នុងការសុំលុបនូវលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលើក្បាលដីលេខៈ ៥៨៥ មានទំហំ ៨៧៧ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែរ ឬទេ?

**គ.២. ចំណុចគ្មានវិវាទៈ**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២កន្លងមក តុលាការកំណត់បានចំណុចគ្មានវិវាទនៃរឿងក្តីមានដូចតទៅ:

-គ្មាន។

**ឃ. សេចក្តីថ្លែងការណ៍របស់គូភាគី**



Scanned with CamScanner

## ឃ.១.សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្ញុំបាទសូមរក្សានូវការសេចក្តីថ្លែងការណ៍របស់ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិដែលបានដាក់ចូលមកតុលាការកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ទុកដដែល និងសូមរក្សានូវកំណត់ហេតុថ្លែងការណ៍របស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] សម្ភស្ស កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ទុកដដែល និងសូមច្រានចោលនូវសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] វណ្ណា ចោលជាអសារបង់ ព្រោះការថ្លែងការណ៍នោះជារឿងមិនពិតចំពោះដីដែលជាកម្មវត្ថុនៃទំនាស់នេះ គឺជាដីកេរ្តិ៍របស់ជីដូនឈ្មោះ [redacted] រ៉ន គឺជាដីកេរ្តិ៍មរតករបស់លោកយាយ [redacted] រ៉ន យ៉ាងពិតប្រាកដ និងសូមរក្សានូវសំណូមពរបស់កូនក្តីខ្ញុំបាទដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ទុកដដែល។ ពាក់ព័ន្ធនឹងមូលហេតុដែលកូនក្តីខ្ញុំបាទបានទាមទារដីខាងលើនេះពីចុងចម្លើយនោះ គឺដោយហេតុថាពាក់ព័ន្ធនឹងមរតករបស់ជីដូនរបស់កូនក្តីខ្ញុំបាទដោយប្រភពដើមនៃដីដែលជាកម្មវត្ថុនៃពាក្យបណ្តឹងនេះ គឺប្រភពដើមរបស់ជីដូនកូនក្តីខ្ញុំបាទ ដោយនៅពេលដែលជីដូនរបស់កូនក្តីខ្ញុំបាទនៅរស់ គឺគាត់បានរក្សាទុកដីនេះឱ្យមកកូនក្តីខ្ញុំបាទ ហើយដោយមានការដឹងឮពីកូនចៅរបស់គាត់ទាំងអស់គ្នាផងដែរ ដោយជីដូនរបស់កូនក្តីខ្ញុំបាទក៏បានរស់នៅជាមួយនឹងជីដូនរបស់គេដែរ។ ហើយក្រោយមកជីដូនរបស់កូនក្តីខ្ញុំបាទបានទទួលមរណភាពដោយបានបន្សល់ទុកនូវដីខាងលើនេះឱ្យមកកូនក្តីខ្ញុំបាទដែលជាចៅរបស់គាត់។ ក្រោយពីជីដូនរបស់កូនក្តីខ្ញុំបាទបានទទួលមរណភាពហើយមក គឺកូនក្តីខ្ញុំបាទបានទៅរស់រកស៊ីនៅឯ[redacted] ហើយក្រោយមកក៏មានការចុះធ្វើប្លង់ដីដែលជាលក្ខណៈប្រព័ន្ធអិលមែប ដោយហេតុថាកូនក្តីខ្ញុំបាទរវល់រកស៊ីនៅឯខេត្តឧត្តរមានជ័យ ទើបកូនក្តីខ្ញុំបាទពុំបានចុះមកធ្វើបណ្ណកម្មសិទ្ធិ ដោយបានសម្រេចឱ្យម្តាយរបស់គេដែលជាចុងចម្លើយឈ្មោះ [redacted] វណ្ណា មកធ្វើប័ណ្ណកម្មសិទ្ធិដាក់ឈ្មោះចុងចម្លើយជាម្ចាស់កម្មសិទ្ធិករ ដោយចុងចម្លើយបានសន្យាថានៅពេលដែលធ្វើប័ណ្ណកម្មសិទ្ធិរួចហើយនោះ គឺចុងចម្លើយនឹងបន្តធ្វើលិខិតផ្ទេរកម្មសិទ្ធិនៃដីដែលបានចុះជាឈ្មោះកម្មសិទ្ធិករនោះឱ្យមកដើមចោទតែម្តង។ ហើយក្រោយមកម្តាយរបស់កូនក្តីខ្ញុំបាទដែលជាចុងចម្លើយក៏បានលិខិតផ្ទេរសិទ្ធិនៃដីខាងលើនេះមួយមកឱ្យកូនក្តីខ្ញុំបាទកាលពីអំឡុងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨។ លុះក្រោយមកនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ ចុងចម្លើយបានឈ្លោះគ្នាជាមួយនឹងប្តីចុងរបស់គាត់ឈ្មោះ [redacted] សីហា ដោយឈ្មោះ [redacted] សីហា បានវាយមកលើម្តាយកូនក្តីខ្ញុំបាទ ពេលនោះកូនក្តីខ្ញុំបាទបានចូលទៅជួយម្តាយរបស់គេក៏ត្រូវបានប្តីចុងឈ្មោះ [redacted] សីហា ចាប់ដៃកាច់ដៃរបស់កូនក្តីខ្ញុំបាទបណ្តាលឱ្យបាក់និងពិការភាពរហូតដល់សព្វថ្ងៃនេះ។ ហើយពាក់ព័ន្ធនឹងរឿងដែលប្តីចុងរបស់ចុងចម្លើយបានកាច់ដៃកូនក្តីខ្ញុំបាទនោះ គឺកំពុងតែដោះស្រាយគ្នានៅតុលាការផងដែរ។ ក្រោយពេលកើតហេតុម្តាយរបស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] វណ្ណា បានមកជួបកូនក្តីខ្ញុំបាទដើម្បីសុំឱ្យនាងខ្ញុំដកពាក្យបណ្តឹងឈប់ប្តឹងពីប្តីចុងរបស់គាត់ឈ្មោះ [redacted] សីហា ដែលបានកាច់បំបាក់ដៃកូនក្តីខ្ញុំបាទ ប៉ុន្តែកូនក្តីខ្ញុំបាទពុំបានយល់ព្រមតាមការស្នើសុំរបស់ចុងចម្លើយនោះទេ និងពុំព្រមដកពាក្យបណ្តឹងនោះទេ។ ហើយនៅពេលដែលកូនក្តីខ្ញុំបាទពុំព្រមតាមការសុំរបស់ម្តាយគេនោះហើយ គឺម្តាយគេឈ្មោះ [redacted] វណ្ណា មានការមិនពេញចិត្ត និងបានឈ្លោះគ្នាជាមួយនាងខ្ញុំចាប់តាំងពីពេលនោះមក។ ហើយចុងចម្លើយឈ្មោះ [redacted] វណ្ណា ក៏បានធ្វើលិខិតលិខិតទប់ស្កាត់លេខៈ១០៨៦ បជ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ដែលមានខ្លឹមសារហាមឃាត់មិនឱ្យ



Scanned with CamScanner

កូនក្ដីខ្ញុំបាទធ្វើការលក់ដូរ ដាក់បញ្ចាំ លើអចលនវត្ថុ ដែលជារបស់កូនក្ដីខ្ញុំបាទ និងបានទាមទារដកហូតយកទៅវិញ។ ហេតុនេះចំពោះពាក់ព័ន្ធនឹងការស្នើសុំដូចមានក្នុងពាក្យបណ្ដឹងរបស់កូនក្ដីខ្ញុំបាទនោះ ពាក់ព័ន្ធនឹងដីទំនាស់នេះ គឺជាដីដែលជាមរតករបស់ជីដូនរបស់កូនក្ដីខ្ញុំបាទឈ្មោះ [redacted] រ៉ន ដែលលោកយាយ [redacted] រ៉ន បានធ្វើអំណោយប្រគល់ឱ្យកូនក្ដីខ្ញុំបាទ និងក្រោយមកចុងចម្លើយបានយល់ព្រមប្រគល់ដោយបានធ្វើលិខិតផ្ទេរសិទ្ធិឱ្យមកកូនក្ដីខ្ញុំបាទដូចមានក្នុងលិខិតផ្ទេរសិទ្ធិស្រាប់។ ហេតុនេះខ្ញុំបាទសូមស្នើសុំដូចមានក្នុងការទាមទារនៃពាក្យបណ្ដឹងទុកដដែល។ ដោយពាក់ព័ន្ធនឹងអង្គហេតុដែលចុងចម្លើយបានលើកឡើងថាបានផ្ទេរដីខាងលើនេះឱ្យមកកូនក្ដីខ្ញុំបាទក្នុងគោលបំណងយកដីខាងលើនេះដើម្បីដាក់បន្ថែមក្រេឌីតក្នុងការទៅរស់នៅសហរដ្ឋអាមេរិកនោះ គឺពុំពិតនោះទេ ដែលការផ្ទេរនេះ គឺចុងចម្លើយសន្យាថានឹងផ្ទេរដីដែលជាមរតករបស់លោកយាយ [redacted] រ៉ន ឱ្យមកកូនក្ដីខ្ញុំបាទតែប៉ុណ្ណោះ ហើយដីខាងលើនេះទៀតសោតចុងចម្លើយត្រូវគោរពតាមការសន្យារបស់គាត់ ដោយនៅពេលដែលធ្វើប្លង់នោះ គឺគាត់ជាអ្នកមកធ្វើជំនួសកូនក្ដីខ្ញុំបាទនៃដីដែលជាមរតករបស់លោកយាយ [redacted] រ៉ន ហើយនៅពេលដែលចុងចម្លើយធ្វើប្លង់រួច គឺគាត់ត្រូវផ្ទេរកម្មសិទ្ធិនៃដីខាងលើនេះឱ្យមកកូនក្ដីខ្ញុំបាទវិញ ពាក់ព័ន្ធនឹងលិខិតដែលចុងចម្លើយបានធ្វើលិខិតផ្ទេរសិទ្ធិនៃដីទំនាស់ខាងលើនេះ គឺថាតើលិខិតផ្ទេរសិទ្ធិនៃដីខាងលើនេះ គឺពុំមែនជាលិខិតអំណោយផ្ដាច់ ឬលិខិតយថាភូតអ្វីនោះទេ ដោយលិខិតនេះគ្រាន់តែជាលិខិតដែលមានគោលបំណងផ្ទេរនៃដីខាងលើនេះឱ្យមកកូនក្ដីខ្ញុំបាទ។ ហេតុនេះខ្ញុំបាទសូមស្នើសុំ ដល់តុលាការសម្រេចពិចារណា និងផ្ដល់យុត្តិធម៌ដល់កូនក្ដីខ្ញុំបាទ។

**ឃ.២.សេចក្ដីថ្លែងការណ៍របស់ដើមចោទ**

-ដើមចោទឈ្មោះ [redacted] សម្ផស្ស បានធ្វើសេក្ដីថ្លែងការណ៍ថាៈ នាងខ្ញុំសុំទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា ធ្វើការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ (ដី) ដែលមានក្បាលដីលេខៈ ៥៨៥ មានទំហំ ៨៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៧ ឱ្យមកនាងខ្ញុំវិញ។ នាងខ្ញុំសូមជម្រាបជូនលោកតុលាការថាៈចំពោះដីដែលមានទំនាស់ខាងលើនេះ គឺដើមឡើយមានទំហំទទឹង ៥ម៉ែត្រ និងបណ្ដោយ ១៤ម៉ែត្រ គឺនាងខ្ញុំបានរស់នៅជាមួយនឹងជីដូនឈ្មោះ [redacted] និងម្ដាយរបស់នាងខ្ញុំឈ្មោះ [redacted] វណ្ណា។ ក្រោយមកនាងខ្ញុំក៏ពុំដឹងថាម្ដាយរបស់នាងខ្ញុំដែលជាចុងចម្លើយបានលែងលះគ្នាជាមួយឪពុករបស់នាងខ្ញុំឈ្មោះ [redacted] សៀន តាំងពីពេលណាមកនោះទេ។ រហូតដល់ពេលដែលនាងខ្ញុំមានអាយុ ១០ឆ្នាំ ទើបដឹងម្ដាយបានយកប្ដីថ្មីទៀត ហើយគាត់បានចេញទៅជាមួយប្ដីថ្មីរកស៊ីនៅខេត្តផ្សេងៗបាត់តែម្ដង។ នៅពេលដែលម្ដាយរបស់នាងខ្ញុំបានចេញទៅរកស៊ីបាត់ៗនៅខេត្តឆ្ងាយៗទៅ គឺនាងខ្ញុំរស់នៅផ្ទះដែលមានទំនាស់ខាងលើជាមួយនឹងយាយឈ្មោះ [redacted] រហូតមកហើយម្ដាយឈ្មោះ [redacted] វណ្ណា ក៏បានមកមើលនាងខ្ញុំ និងយាយម្ដងម្កាលដែរ។ ក្រោយមកនៅក្នុងឆ្នាំ ១៩៩៩ យាយនាងខ្ញុំបានធ្លាក់ខ្លួនឈឺ ហើយម្ដាយឈ្មោះ [redacted] វណ្ណា បានត្រឡប់មកផ្ទះវិញ ហើយនៅក្នុង២០០០ យាយនាងខ្ញុំក៏បានស្លាប់ទៅ។ នាងខ្ញុំសូមបញ្ជាក់ផងដែរថាៈ ចំពោះដីខាងលើនេះ គឺដើមកំណើតដំបូងឡើយជាដីកម្មសិទ្ធិរបស់យាយនាងខ្ញុំ ដែលនាងខ្ញុំបានរស់នៅជាមួយគាត់តាំងពីតូចមកដោយដីនេះពុំមានបណ្ណកម្មសិទ្ធិប្លង់រឹងនោះទេ ហើយមុនពេលដែលយាយនាងខ្ញុំបានស្លាប់ទៅគាត់បានផ្ដាំថាដីខាងលើនេះគឺទុកឱ្យនាងខ្ញុំដែលជាចៅបង្កើត ដោយនៅពេលប្រាប់នោះ គឺមានឈ្មោះ [redacted] មាន

ហេង ភេទប្រុស និងឈ្មោះ [redacted] សុខុម ភេទស្រី ដែលបានដឹងឮអំពីដីខាងលើនេះ។ ហើយក្រោយមកនៅក្នុងឆ្នាំ២០០៥ នាងខ្ញុំបានទិញបន្ថែមពីលើដីខាងលើដែលមានស្រាប់គឺទំហំទទឹង៥ម៉ែត្រ និងបណ្តោយ ១៤ម៉ែត្រ ដោយបានទិញបន្ថែមមានទំហំទទឹង ៥ម៉ែត្រ និងបណ្តោយ ៤ម៉ែត្រ បានទិញពីយាយឈ្មោះ [redacted] គឺ តម្លៃ ៧៥០$ ដែលសរុបទាំងអស់ គឺដីខាងលើមានទំហំទទឹង៥ម៉ែត្រ និងបណ្តោយ ១៨ម៉ែត្រ។ ក្រោយមកនៅក្នុងឆ្នាំ២០០៧នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ ហើយនៅពេលនាងខ្ញុំរៀបអាពាហ៍ពិពាហ៍រួច គឺនាងខ្ញុំបានធ្វើការសាងសង់ផ្ទះបន្ថែមពីលើផ្ទះរបស់យាយនាងខ្ញុំដែលមានស្រាប់នៅពីលើដីនោះ។ ហើយនៅក្នុងឆ្នាំ២០០៨ ម្តាយនាងខ្ញុំបានហៅនាងខ្ញុំឱ្យទៅរកស៊ីជាមួយគាត់នៅឯស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ហើយនាងខ្ញុំក៏បានទៅរកស៊ីនៅទីនោះទៅ ហើយចំពោះផ្ទះខាងលើក៏ត្រូវបានដាក់ជួលទៅឱ្យគេដើម្បីបើកហាងលក់ដូរចាប់តាំងពីពេលនោះរហូតមកដល់ពេលបច្ចុប្បន្ននេះ ចំពោះប្រាក់ថ្លៃឈ្នួលនោះ គឺជួនកាលនាងខ្ញុំជាអ្នកទទួល ជួនកាលក៏ម្តាយនាងខ្ញុំឈ្មោះ [redacted] វណ្ណា ជាអ្នកទទួលផងដែរ។ ក្រោយមកនៅក្នុងឆ្នាំ២០១៧ ខាងអាជ្ញាធរដែនដីបានចុះធ្វើការវាស់វែងដីដើម្បីចែកជូនប្រជាពលរដ្ឋជាលក្ខណៈប្រព័ន្ធនៅស្រុកត្រាំកក់ ខេត្តតាកែវ ហើយនាងខ្ញុំក៏បានឱ្យម្តាយមកធ្វើការចុះបញ្ជីដីនោះជាមួយនឹងខាងមន្ត្រីសុរិយោដីនៅខេត្តតាកែវ ជំនួសនាងខ្ញុំដោយនៅពេលនោះ គឺនាងខ្ញុំនៅជាប់រកស៊ីនៅខេត្តឧត្តមានជ័យ។ មូលហេតុដែលនាងខ្ញុំឱ្យម្តាយមកធ្វើការចុះបញ្ជីដីខាងលើដោយសារម្តាយរបស់នាងខ្ញុំ គឺគាត់ត្រូវមកចុះបញ្ជីដីរបស់គាត់ដែរ ហើយម្តាយរបស់នាងខ្ញុំគាត់ក៏បានប្រាប់នាងខ្ញុំថាៈ គាត់ចុះមកខេត្តតាកែវធ្វើការចុះបញ្ជីឱ្យហើយគាត់នឹងផ្ទេរដីនោះមកឱ្យនាងខ្ញុំវិញ។ ក្រោយម្តាយរបស់នាងខ្ញុំបានឡើងមកពីខេត្តបន្ទាយមានជ័យ មកខេត្តតាកែវដើម្បីមកធ្វើប្លង់ទាំងនោះទៅ។ ក្រោយមកនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមន្ទីរក៏បានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ មកឱ្យម្តាយនាងខ្ញុំ។ ហើយនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ម្តាយនាងខ្ញុំក៏បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីដែលគាត់បានមកចុះបញ្ជីនៅពេលដែលមន្ត្រីសុរិយោដីហៅធ្វើប័ណ្ណកាលពីឆ្នាំ២០១៧ នោះមកឱ្យនាងខ្ញុំដូចការសន្យាមែន។ ក្រោយពីម្តាយបានធ្វើលិខិតផ្ទេរសិទ្ធិខាងលើមកឱ្យនាងខ្ញុំរួចហើយ នាងខ្ញុំ និងម្តាយក៏ពុំបាននាំគ្នាមកធ្វើការកាត់ឈ្មោះលើបណ្ណខាងលើនោះដែរ ដោយនាងខ្ញុំសំអាងថាជាម្តាយនឹងកូននឹងគ្នា ហើយនាងខ្ញុំក៏បានយកលិខិតផ្ទេរសិទ្ធិ រួមទាំងប្លង់រឹងនោះមករក្សាទុករហូតដល់បច្ចុប្បន្ននេះ។ លុះនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ ម្តាយនាងខ្ញុំបានឈ្លោះគ្នាជាមួយនឹងប្តីចុងរបស់គាត់ឈ្មោះ [redacted] សីហា ដោយឈ្មោះ [redacted] សីហា បានវាយមកលើម្តាយនាងខ្ញុំឈ្មោះ [redacted] វណ្ណា ដោយបានទះមុខម្តាយនាងខ្ញុំ និងប្រតាយប្រតប់ម្តាយនាងខ្ញុំ ពេលឃើញដូចនោះនាងខ្ញុំក៏បានចូលទៅជួយម្តាយក៏ត្រូវឈ្មោះ [redacted] សីហា ចាប់ដៃរបស់នាងខ្ញុំផ្តោបចូលគ្នា និងបានកាច់ដៃនាងខ្ញុំផ្តួបចូលគ្នារហូតទាល់តែបាក់កំផួនដៃខាងឆ្វេង ហើយតុលាការនៃសាលាដំបូងខេត្តឧត្តរមានជ័យក៏បានសម្រេចចេញសាលក្រមផ្តន្ទាទោសលើប្តីចុងរបស់ម្តាយនាងខ្ញុំផងដែរ ដោយគាត់បានជាប់ពន្ធនា គារនៅខេត្តនោះ។ ក្រោយពេលកើតហេតុម្តាយរបស់នាងខ្ញុំឈ្មោះ [redacted] វណ្ណា បានមកជួបនាងខ្ញុំដើម្បីសុំឱ្យនាងខ្ញុំដកពាក្យបណ្តឹងឈប់ប្តឹងពីប្តីចុងរបស់គាត់ឈ្មោះ [redacted] សីហា ដែលបានកាច់បំបាក់ដៃនាងខ្ញុំ ប៉ុន្តែនាងខ្ញុំពុំព្រមដកនោះទេ។ ហើយនៅពេលដែលនាងខ្ញុំពុំព្រមតាមការសុំរបស់ម្តាយនោះហើយ គឺម្តាយនាងខ្ញុំឈ្មោះ [redacted] វណ្ណា មានការមិនពេញចិត្ត និងបានឈ្លោះគ្នាជាមួយនាងខ្ញុំចាប់តាំងពីពេលនោះមក។ លុះមកដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ម្តាយខ្ញុំឈ្មោះ [redacted] វណ្ណា គាត់បានទៅធ្វើលិខិតទប់ស្កាត់លេខៈ ១០៨៦

បជ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ដែលមានខ្លឹមសារហាមឃាត់មិនឱ្យធ្វើការលក់ដូរ ដាក់បញ្ចាំ លើអចលនវត្ថុដែលជារបស់នាងខ្ញុំទៅវិញ ដោយគាត់បានលើកយកមូលហេតុនៅក្នុងលិខិតទប់ស្កាត់ខាងលើនោះថា: "**ដោយដីខាងលើនាងខ្ញុំបានផ្ទេរសិទ្ធិឱ្យកូនឈ្មោះ [redacted] សម្ផស្ស ម្តងរួច ហើយ ប៉ុន្តែមកដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ នាងខ្ញុំសូមបដិសេធសិទ្ធិដែលប្រគល់ឱ្យនោះវិញ**" មិនតែប៉ុណ្ណោះម្តាយនាងខ្ញុំក៏បានទៅជួបជាមួយនឹងអ្នកដែលបានជួលដីរបស់នាងខ្ញុំ និងបានគំរាមថាឈប់ឱ្យជួលដីនោះពីនាងខ្ញុំទៀតទៅ។ លុះនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ប្តីចុងម្តាយរបស់នាងខ្ញុំឈ្មោះ [redacted] សីហា បានទៅវាយសោរផ្ទះរបស់នាងខ្ញុំដែលបានដាក់ជួលឱ្យគេនោះ ដោយមានអ្នកជួលផ្ទះរបស់នាងខ្ញុំបានខលមកប្រាប់នាងខ្ញុំ។ ហើយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ នាងខ្ញុំក៏បានមកសម្របសម្រួល និងហៅឪពុកចុងនាងខ្ញុំឱ្យទៅសន្យាគ្នានៅប៉ុស្តិ៍ប៉ូលីសម្តងរួចហើយ ក្រោយមកប្តីចុងម្តាយនាងខ្ញុំក៏បានធ្វើការអុកឡុក និងកាត់សោរជាហូរហែរម្តងទៀត ហើយនាងខ្ញុំក៏បានហៅគាត់ទៅដោះស្រាយគ្នានៅសាលាឃុំ ដោយមានធ្វើកំណត់ហេតុរួមសន្យារួមគ្នាផងដែរ។ មូលហេតុទាំងអស់នេះហើយដែលជាហេតុធ្វើឱ្យនាងខ្ញុំនៅតែសុំទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា ធ្វើការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុខាងលើនេះមកឱ្យនាងខ្ញុំ ហើយមួយចំណែកទៀតដីខាងលើនេះជាដីកេរ្តិ៍របស់យាយនាងខ្ញុំដែលបានសន្យាថាប្រគល់មកឱ្យនាងខ្ញុំផងដែរ ដោយមានសាក្សីដឹងឮត្រឹមត្រូវហើយមួយចំណែកទៀតនៃដីខាងលើនោះក៏នាងខ្ញុំបានចូលរួមចំណែកទិញផងដែរ។ ចំពោះដីខាងលើនេះ គឺជាដីកេរ្តិ៍របស់យាយនាងខ្ញុំ ដោយនាងខ្ញុំបានរស់នៅជាមួយនឹងយាយរបស់នាងខ្ញុំរហូតដល់គាត់ទទួលមរណភាព ហើយនាងខ្ញុំបានរស់នៅនឹងមើលថែរយាយនាងខ្ញុំរហូតដល់ថ្ងៃគាត់ទទួលមរណភាព ក្រោយពេលដែលយាយរបស់នាងខ្ញុំបានទទួលមរណភាពហើយនោះ គឺម្តាយនាងខ្ញុំឈ្មោះ [redacted] វណ្ណា បានហៅនាងខ្ញុំឱ្យទៅរកស៊ីជាមួយនឹងគាត់នៅឯខេត្តឧត្តរមានជ័យ។

### ឃ.៣.សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: ពាក់ព័ន្ធនឹងដីទំនាស់ខាងលើនេះ គឺជាកម្មសិទ្ធិស្របច្បាប់របស់កូនក្តីខ្ញុំបាទដែលជាដីរបស់កូនក្តីខ្ញុំបាទបានរកស៊ីទិញដោយខ្លួនឯងជាមួយនឹងប្តីក្រោយរបស់គាត់ និងបបានទិញបន្ថែមដោយមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ផងដែរ។ ហើយចំពោះដីខាងលើនេះទៀតសោត គឺកូនក្តីខ្ញុំបាទក៏បានទិញបន្ថែមនូវកន្ទុយដីខាងក្រោយបន្ថែមទៀតដែលមានតម្លៃ ៣តម្លឹង ដោយកូនក្តីរបស់ខ្ញុំបាទបានរស់នៅលើដីនោះរហូតមក។ ហើយក្រោយមកនៅក្នុងឆ្នាំ ១៩៩៣ ដោយសារតែមានបញ្ហាជីវភាពទើបកូនក្តីខ្ញុំបាទបានផ្លាស់ប្តូរទីលំនៅដោយទៅរស់នៅឯត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងបានប្រកបរបររកស៊ីនៅទីនោះទៅ និងបានយកកូនស្រីដែលជាដើមចោទទៅរស់នៅជាមួយនឹងកូនក្តីខ្ញុំបាទផងដែរ។ លុះក្រោយមកនៅក្នុងឆ្នាំ២០១៨ ដើមចោទក៏មានបំណងទៅរស់នៅសហរដ្ឋអាមេរិក និងដើមចោទបានស្នើសុំឱ្យកូនក្តីខ្ញុំបាទធ្វើការផ្ទេរនូវដីមួយចំនួនឱ្យទៅគាត់ដើម្បីឱ្យគាត់មានក្រេឌីតក្នុងការស្នើសុំវីសាទៅរស់នៅឯសរដ្ឋអាមេរិក ទើបកូនក្តីខ្ញុំបាទបានធ្វើលិខិតផ្ទេរកម្មសិទ្ធិឱ្យទៅចុងចម្លើយតែម្តងទៅ ប៉ុន្តែចំពោះការធ្វើលិខិតផ្ទេរនូវដីខាងលើនេះ គឺកូនក្តីខ្ញុំបាទពុំបានផ្ទេរឱ្យទៅដើមចោទនូវសិទ្ធិទាំងស្រុងនោះទេ ដោយគ្រាន់តែឱ្យកាន់កាប់តែប៉ុណ្ណោះ។ ហើយក្រោយមកដើមចោទក៏មានទំនាស់ជាមួយនឹងកូនក្តីខ្ញុំបាទ និងបានជេរប្រមាថមកលើកូនក្តីខ្ញុំបាទជាច្រើន ដោយបានដេញកូនក្តីខ្ញុំបាទចេញពីផ្ទះទៀតផងដែរ ដោយ

សារតែអំពើដែលដើមចោទបានធ្វើបាបមកលើកូនក្តីខ្ញុំបាទយ៉ាងច្រើនបែបនេះទើបកូនក្តីខ្ញុំបាទបានធ្វើលិខិតទប់ស្កាត់នៃដីខាងលើនេះវិញ ដោយបានចារឹកថាៈ "ដោយដីខាងលើនាងខ្ញុំបានផ្ទេរសិទ្ធិឱ្យកូនឈ្មោះ [redacted] សម្ផស្ស ម្តងរួចហើយ ប៉ុន្តែមកដល់ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ នាងខ្ញុំសូមបដិសេធសិទ្ធិដែលប្រគល់ឱ្យនោះវិញ" រឿងហេតុទាំងអស់នេះហើយទើបកូនក្តីខ្ញុំបាទពុំយល់ព្រមតាមការទាមទាររបស់ដើមចោទនោះទេ។ ហេតុនេះខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ គឺសូមស្នើសុំដល់តុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទចោលទាំងស្រុង។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថាៈ ពាក់ព័ន្ធនឹងមូលហេតុដែលកូនក្តីខ្ញុំបាទបានស្នើសុំដល់តុលាការដើម្បីស្នើសុំលុបលើលិខិតផ្ទេរសិទ្ធិនៃដីខាងលើនេះ និងដកហូតពីដើមចោទនោះ គឺដោយហេតុថាពាក់ព័ន្ធនឹងកូនក្តីខ្ញុំបាទបានផ្ទេរដីខាងលើនេះ គឺផ្ទេរដើម្បីឱ្យដើមចោទបានបំពេញក្រេឌីតដើម្បីទៅរស់នៅសហរដ្ឋអាមេរិក ហើយក្រោយមកដើមចោទក៏ពុំបានទៅរស់នៅសហរដ្ឋអាមេរិកនោះទេ និងបានចង់ស៊ីដាច់នៃដីរបស់កូនក្តីខ្ញុំបាទ ហើយចំពោះការធ្វើលិខិតផ្ទេរដីខាងលើនេះទៀតសោត គឺកូនក្តីខ្ញុំបាទពុំបានផ្ទេរសិទ្ធិឱ្យដាច់នោះទេ ដោយគ្រាន់តែបានឱ្យប្រើប្រាស់តែប៉ុណ្ណោះ មួយវិញទៀតចំពោះលិខិតផ្ទេរសិទ្ធិនោះទៀតសោត គឺពុំធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់នោះទេ ហើយតាមការអះអាងរបស់កូនក្តីខ្ញុំបាទថាកូនរបស់គាត់ដែលជាដើមចោទ គឺមានភាពអកត្តញ្ញូចំពោះម្តាយ ដោយបានជេរប្រមាថមកលើម្តាយរបស់គេដែលជាកូនក្តីខ្ញុំបាទយ៉ាងច្រើន។ ហេតុនេះទើបបានជាខ្ញុំបាទសូមស្នើសុំដល់លោកចៅក្រមសម្រេចច្រានចោលការទាមទាររបស់ដើមចោទចោល ដោយសុំប្រគល់ដីខាងលើនេះឱ្យមកកូនក្តីខ្ញុំបាទវិញ។ ពាក់ព័ន្ធនឹងដីខាងលើនេះ គឺជាដីរបស់កូនក្តីខ្ញុំបាទដែលបានមកពីការទិញដោយខ្លួនគាត់តែប៉ុណ្ណោះ ដោយពុំមែនបានមកពីមរតករបស់លោកយាយ [redacted]វ៉ន នោះទេ ដោយជាដីដែលបានមកពីកម្លាំងញើសឈាមរបស់កូនក្តីខ្ញុំបាទនោះឯង។ មួយវិញទៀតពាក់ព័ន្ធនឹងដីខាងលើនេះ គឺជាដីដែលបានចុះបញ្ជីប្លង់រឹង គឺការផ្ទេរនោះត្រូវតែធ្វើនីតិវិធីផ្ទេរតាមនីតិវិធីប្លង់រឹង និងឱ្យបានត្រឹមត្រូវតាមបញ្ញត្តិមាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី។ ហេតុនេះខ្ញុំបាទសូមស្នើសុំដល់តុលាការមេត្តាសម្រេចច្រានចោលការទាមទាររបស់ដើមចោទចោលទាំងស្រុង។

ឃ.៤. សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

-ចុងចម្លើយឈ្មោះ [redacted] វណ្ណា បានធ្វើសេក្តីថ្លែងការណ៍ថាៈ នាងខ្ញុំពិតជាបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរំពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ឱ្យទៅកូនស្រីឈ្មោះ[redacted]សម្ផស្ស ពិតប្រាកដមែន ហើយមកដល់ពេលនេះនាងខ្ញុំសូមបដិសេធចំពោះការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីនោះចោលពុំឱ្យទៅឈ្មោះ [redacted] សម្ផស្ស នោះវិញទេ។ ចំពោះដីដែលនាងខ្ញុំបានផ្ទេរឱ្យទៅឈ្មោះ [redacted] សម្ផស្ស នោះ គឺនាងខ្ញុំបានកាន់កាប់តាំងពីឆ្នាំ១៩៨៣ ដោយនាងខ្ញុំបានទិញពីអ្នកជិតខាងឈ្មោះ គី និងឈ្មោះ [redacted]តាំងពីជំនាន់អ៊ុនតាក់មកម្លេះ ដោយចាប់ពីពេលទិញដីខាងលើនោះមក គឺនាងខ្ញុំរស់នៅលើដីនោះជាមួយនឹងម្តាយនាងខ្ញុំឈ្មោះ[redacted] វ៉ន, ឈ្មោះ [redacted]សម្ផស្ស, ឈ្មោះ[redacted] និងមានតូបមួយនៅពីលើនោះ ដោយបានបើករបរលក់ដូរនោះរហូតមក។ រហូតមកដល់ឆ្នាំ២០០៣ នាងខ្ញុំទៅរស់នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដោយនាងខ្ញុំរកស៊ីនៅទីនោះប្រកបរបរកុងស៊ីសត្វឃាត(កន្លែងធ្វើជ្រូក)។ ហើយក្រោយមកនៅអំឡុងឆ្នាំ២០១៨ កូនស្រីរបស់នាងខ្ញុំឈ្មោះ [redacted] សម្ផស្ស គាត់មានបំណងចង់ទៅរស់នៅសហរដ្ឋអាមេរិកជាមួយនឹងប្តីរបស់គាត់ ហើយឈ្មោះ [redacted]

សម្ភស្ស ដែលជាចុងចម្លើយបានប្រាប់មកនាងខ្ញុំថាៈ ឱ្យនាងខ្ញុំផ្ទេរនូវទ្រព្យសម្បត្តិមួយចំនួនឱ្យទៅគេ ដើម្បីឱ្យគេមានក្រេដីតក្នុងការសម្ភាសន៍បានទៅរស់នៅសហរដ្ឋអាមេរិក ហើយនៅពេលនោះនាងខ្ញុំក៏បានយល់ព្រមនឹងកូន និងបានផ្ទេរឱ្យទៅគេជាបណ្តោះអាសន្នដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ដោយមានអាជ្ញាធរភូមិ និងឃុំដឹងឮផងដែរ។ ក្រោយមកនៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២០ នាងខ្ញុំក៏បានធ្វើលិខិតស្នើសុំទប់ស្កាត់រក្សាការពារដល់ភូមិឃុំផងដែរ ដោយបដិសេធក្នុងការធ្វើអំណោយនូវដីខាងលើនោះឱ្យទៅដើមចោទ ចំពោះមូលហេតុដែលនាងខ្ញុំបដិសេធ គឺដោយសារឈ្មោះ [redacted]សម្ភស្ស គាត់បានកុហកនាងខ្ញុំ ដោយគេពុំបានទៅសហរដ្ឋអាមេរិកនោះទេ ហើយមួយចំណែកទៀតគាត់ពុំស្គាល់ម្តាយ និងពុំមានគុណធម៌ជាមួយនាងខ្ញុំព្រមទាំងពុំបានចិញ្ចឹមនាងខ្ញុំក្នុងនាមជាម្តាយនោះទេ ហេតុដូច្នេះហើយទើបគាត់ចង់យកដីខាងលើនេះជាកម្មសិទ្ធិផ្តាច់មុខ។ មកដល់ពេលនេះនាងខ្ញុំសូមបដិសេធក្នុងការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីខាងលើនោះឱ្យទៅឈ្មោះ [redacted] សម្ភស្ស នោះចោល ដោយនាងខ្ញុំសូមដកយកដីខាងលើនេះមករក្សាទុកវិញ ដោយដីខាងលើនេះជាដីរបស់នាងខ្ញុំដែលបានទិញពីឈ្មោះ គី និងឈ្មោះ [redacted] ដោយពុំមែនជាដីកេរ្តិ៍របស់ម្តាយនាងខ្ញុំឈ្មោះ [redacted] រ៉ន នោះទេ ដោយម្តាយនាងខ្ញុំឈ្មោះ [redacted] រន នោះគឺគាត់មករស់នៅជាមួយនឹងនាងខ្ញុំតែប៉ុណ្ណោះ។

ឃ.៤.សេចក្តីបំភ្លឺរបស់សាក្សី

-សាក្សីឈ្មោះ [redacted] គី បានឆ្លើយបំភ្លឺថាៈ នាងខ្ញុំមកនេះជាសាក្សីរបស់ចុងចម្លើយ ចំពោះប្រវត្តិនៃដីខាងលើនេះ គឺកាលពីដើមឡើយជាដីរបស់នាងខ្ញុំ ហើយនាងខ្ញុំក៏បានលក់ដីដែលកំពុងតែមានទំនាស់ខាងលើនេះលក់ឱ្យទៅឈ្មោះ [redacted] វណ្ណា ហៅ ស្រី ដែលមានទំហំទទឹង ៥ម៉ែត្រ ចំណែកឯបណ្តោយ គឺនាងខ្ញុំពុំចាំនោះទេដោយហេតុថានាងខ្ញុំបានលក់ដីខាងលើនេះតាំងពីយូរណាស់មកហើយ។ ចំពោះយាយឈ្មោះ [redacted] រ៉ន គឺនាងខ្ញុំបានដឹងថាគាត់រស់នៅទីតាំងទំនាស់ខាងលើ ដោយគាត់បានរស់នៅជាមួយនឹងកូនរបស់គាត់ឈ្មោះ ស្រី ចំណែកឯពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីខាងលើនេះ គឺនាងខ្ញុំពុំដឹងច្បាស់នោះទេ។ ចំពោះលោកយាយឈ្មោះ [redacted] រ៉ន គឺកន្លងមកគាត់បានរស់នៅលើដីទំនាស់ខាងលរហូតដល់គាត់ស្លាប់ទៅក៏បានស្លាប់នៅលើដីខាងលើនេះដែរ។ ចំពោះដីខាងលើដែលនាងខ្ញុំបានលក់កន្លងមក គឺពុំមានលិខិតអ្វីនោះទេ ដោយហេតុថាលក់តាំងពីយូរណាស់មកហើយ។ ចំពោះឈ្មោះ [redacted] វណ្ណា ហៅ ស្រី បានមកទិញដីពីនាងខ្ញុំ គឺបានមកពីរនាក់ប្តីរបស់គេ។

-សាក្សីឈ្មោះ [redacted] វណ្ណា បានឆ្លើយបំភ្លឺថាៈ នាងខ្ញុំជាអ្នកជិតខាងដែលបានរស់នៅជិតដីទំនាស់ខាងលើ នេះ ហើយនាងខ្ញុំមកនេះ គឺនាងខ្ញុំបានដឹងថាដីខាងលើនេះ គឺឈ្មោះ [redacted] គី បានលក់ឱ្យទៅឈ្មោះ [redacted] វណ្ណា តាំងពីឆ្នាំកៅសិបជាង។ ហើយចំពោះឈ្មោះ[redacted] រ៉ន គឺគាត់ទើបបានមករស់នៅលើដីខាងលើនេះ។ ចំពោះរឿងហេតុអ្វីផ្សេងទៀតនាងខ្ញុំពុំដឹងនោះទេ។

-សាក្សីឈ្មោះ [redacted] វណ្ណៈ បានឆ្លើយបំភ្លឺថាៈ នាងខ្ញុំត្រូវជាបងជីដូនមួយរបស់ឈ្មោះ [redacted] វណ្ណា ដោយពាក់ព័ន្ធនឹងដីខាងលើនេះ គឺនាងខ្ញុំបានដឹងថាប្អូនជីដូនមួយរបស់នាងខ្ញុំឈ្មោះ [redacted] វណ្ណា ហៅ ស្រី បានមកខ្ចីលុយពីនាងខ្ញុំដើម្បីយកមកទិញដីខាងលើនេះ ក្រោយមកនាងខ្ញុំក៏បានយល់ព្រមប្រគល់ប្រាក់ឱ្យមកប្អូនជីដូនមួយរបស់នាងខ្ញុំដើម្បីយកមកទិញដីខាងលើនេះជាមួយនឹងប្តីរបស់គេឈ្មោះ សីហា តែម្តងទៅ។ ពាក់ព័ន្ធនឹងការផ្ទេរដីខាងលើនេះឱ្យទៅឈ្មោះ [redacted] សម្ភស្ស នោះ គឺនាងខ្ញុំដឹងថាប្អូនជីដូនមួយរបស់នាងខ្ញុំបានផ្ទេរឱ្យទៅឈ្មោះ [redacted] សម្ភស្ស ដើម្បីបានរក្សាក្រេឌីត និងរត់ឯកសារទៅរស់

នៅឯសហរដ្ឋអាម៉េរិក។ នាងខ្ញុំដឹងថាដីទំនាស់ខាងលើនេះ នាងខ្ញុំបានដឹងថាដីនេះពុំមែនជាដីរបស់មីង នាងខ្ញុំឈ្មោះ [redacted] រ៉ន នោះទេ ដោយដីនេះជាដីរបស់ប្អូនឈ្មោះ [redacted] វណ្ណា គាត់បានខ្ចីប្រាក់ពីនាងខ្ញុំ ដើម្បីយកទៅទិញដីខាងលើនេះ។

-សាក្សីឈ្មោះ [redacted] សុខុម បានឆ្លើយបំភ្លឺថា: នាងខ្ញុំត្រូវជាបងជីដូនមួយរបស់ឈ្មោះ [redacted] វណ្ណា ដោយពាក់ព័ន្ធនឹងបញ្ហាដែលមានទំនាស់នៃដីខាងលើនេះ គឺនាងខ្ញុំដឹងថាគ្រួសារខាងលើនេះតែងមានបញ្ហាជាមួយគ្នាញឹកញាប់ណាស់ចាប់តាំងពីពេលដែលប្តីដើមរបស់គាត់បានទទួលមរណភាពរួចមក។ ហើយពាក់ព័ន្ធនឹងប្រវត្តិដីទំនាស់ខាងលើនេះ គឺនាងខ្ញុំបានដឹងថាអ៊ុំស្រីរបស់នាងខ្ញុំឈ្មោះ [redacted] រ៉ន បានយកមាសរបស់គាត់ដែលសន្សំបានកន្លងមក និងដែលបានយកមកផ្ញើរនាងខ្ញុំឱ្យទុកឱ្យគាត់ គឺគាត់បានយកមាសនោះទៅលក់ដើម្បីយកប្រាក់ទិញដីដែលកំពុងមានទំនាស់ខាងលើនោះ ហើយនៅពេលទិញនោះ គឺគាត់បានខ្វះប្រាក់បន្តិចបន្តួចដើម្បីទិញដីនោះ រួចហើយនាងខ្ញុំបានដកលុយបាតរបស់នាងខ្ញុំមួយចំនួនដើម្បីឱ្យទៅគាត់បង្គ្រប់ក្នុងការទិញដីខាងលើនោះ ក្រោយពេលទិញរួច គឺអ៊ុំស្រីរបស់នាងខ្ញុំឈ្មោះ [redacted] រ៉ន បានរស់នៅលើដីខាងលើនោះ និងបាននិយាយប្រាប់នាងខ្ញុំថាចំពោះដីខាងលើនេះ គឺគាត់នឹងរក្សាទុកចែកឱ្យទៅចៅរបស់គាត់ឈ្មោះ [redacted] សម្ផស្ស ដោយហេតុថាចៅរបស់គាត់ឈ្មោះ [redacted] សម្ផស្ស នេះ គឺកំសត់តាំងពីដើមមក ហើយគាត់ក៏បានយល់ព្រមផ្ទេរដីខាងលើនេះឱ្យទៅចៅរបស់គាត់ ប៉ុន្តែចំពោះការផ្ទេរនោះទៀតសោត គឺពុំបានធ្វើលិខិតផ្ទេរនោះទេ ប៉ុន្តែនាងខ្ញុំបានដឹងថាអ៊ុំស្រីរបស់នាងខ្ញុំឈ្មោះ [redacted] រ៉ន គឺគាត់បានយល់ព្រមផ្ទេរដីនោះឱ្យទៅចៅរបស់គាត់ឈ្មោះ [redacted] សម្ផស្ស។ ចំពោះសព្វថ្ងៃនេះ គឺនាងខ្ញុំរស់នៅឯខេត្តកំពតឯណោះ ដោយពុំបានមករស់នៅជិតលើដីដែលមានទំនាស់ខាងលើនេះនោះទេ មួយវិញទៀតដីខាងលើនេះ គឺនាងខ្ញុំគ្រាន់តែបានជិះកាត់នៅពេលដែលនាងខ្ញុំឡើងទៅភ្នំពេញម្តងៗ គឺនាងខ្ញុំតែងតែជិះកាត់ និងឈប់នៅលើដីនោះជាញឹកញាប់។ ចំពោះលោកយាយ ទែន រ៉ន ដែលជាអ៊ុំស្រីរបស់នាងខ្ញុំគាត់បានមករស់នៅលើដីខាងលើនេះតាំងពីបែកប៉ុលពតមកម្លេះ។ ហើយពាក់ព័ន្ធនឹងអ៊ុំស្រីរបស់នាងខ្ញុំឈ្មោះ [redacted] រ៉ន ទិញដីមកពីអ្នកណា ទិញនៅកន្លែងណា និងទំហំប៉ុន្មាននោះ គឺនាងខ្ញុំពុំដឹងនោះទេ។ នាងខ្ញុំសូមបញ្ជាក់ថា: ចំពោះប្រវត្តិដីខាងលើនេះ គឺជាដីរបស់អ៊ុំស្រីឈ្មោះ [redacted] រ៉ន ដែលបានទិញកន្លងមក និងបានរក្សាទុកឱ្យទៅចៅរបស់គាត់ឈ្មោះ [redacted] សម្ផស្ស។

-សាក្សីឈ្មោះ [redacted] មានហេង បានឆ្លើយបំភ្លឺថា: ខ្ញុំបាទត្រូវជាកូនរបស់ឈ្មោះ [redacted] រ៉ន បងបង្កើតរបស់ឈ្មោះ [redacted] វណ្ណា និងត្រូវជាពូរបស់ឈ្មោះ [redacted] សម្ផស្ស ដោយពាក់ព័ន្ធនឹងដីដែលមានទំនាស់ខាងលើនេះ គឺខ្ញុំបាទបានដឹងថាដីខាងលើនេះ គឺមានឈ្មោះ [redacted] វណ្ណា បានមករស់នៅលើដីខាងលើនេះមុន ហើយក្រោយមកម្តាយខ្ញុំបាទឈ្មោះ [redacted] រ៉ន បានមករស់នៅលើដីខាងលើនេះដែរ ហើយពាក់ព័ន្ធនឹងដីខាងលើនេះ គឺខ្ញុំបាទពុំបានដឹងថាជារបស់អ្នកណាឱ្យប្រាកដនោះទេ ដោយហេតុថានៅពេលនោះ គឺពួកយើងរស់នៅជុំគ្នា និងខ្ញុំបាទពុំចាប់អារម្មណ៍ថាដីនេះជាកម្មសិទ្ធិរបស់អ្នកណានោះទេ ប៉ុន្តែខ្ញុំបាទគ្រាន់តែបានដឹងថាម្តាយរបស់ខ្ញុំបាទបានកាន់កាប់ប្រាក់ទាំងអស់ដែលកូនៗរកស៊ីបាន។

**៦កសារដែលដើមចោទស្នើសុំឱ្យតុលាការពិនិត្យ:**

១-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ២១០៩១៣០៣-០៥៨៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។

២-លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ: ៣៤៨ ប.ជ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨។



Scanned with CamScanner

៣-កិច្ចសន្យាជួលដី និងផ្ទះចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨។

៤-កិច្ចសន្យាជួលដី និងផ្ទះ (បន្ត) ចុះថ្ងៃ១៥ ខែតុលា ឆ្នាំ២០២០។

៥-សាលក្រមព្រហ្មទណ្ឌលេខៈ ០១ (ក) ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ០១៨ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។

៦-លិខិតស្នើសុំទប់ស្កាត់រក្សាការពារលេខៈ ១០៨៦ បជ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០។

៧-កំណត់ហេតុសាកសួរឈ្មោះ [redacted] សម្ផស្ស។

៨-កំណត់ហេតុសាកសួរឈ្មោះ [redacted] វណ្ណា។

៩-លិខិតស្នើសុំលប់កិច្ចសន្យាជួលផ្ទះរវាងឈ្មោះ [redacted] សម្ផស្ស និងឈ្មោះ [redacted] សីហា។

១០-កំណត់ហេតុសាកសួរឈ្មោះ [redacted] វណ្ណា ។

១១-កំណត់ហេតុសាកសួរឈ្មោះ [redacted] វណ្ណា។

**ឯកសារដែលសហចុងចម្លើយស្នើសុំឱ្យតុលាការពិនិត្យៈ**

១-លិខិតឆ្លើយបំភ្លឺចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ពៅ។

២-ពាក្យឆ្លើយបំភ្លឺចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ណេ, ឈ្មោះ [redacted] បឿន ឈ្មោះ [redacted] ណែម, ឈ្មោះ [redacted] មុំ, ឈ្មោះ [redacted] សូលី, ឈ្មោះ [redacted] ណារ៉ា, ឈ្មោះ [redacted] ណម, ឈ្មោះ [redacted] រិទ្ធី, ឈ្មោះ [redacted] សារិន និងឈ្មោះ [redacted] សាមុី។

៣-ពាក្យសុំធ្វើជាសាក្សីចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] គី។

៤-ពាក្យសុំធ្វើជាសាក្សីចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ហ៊ិន។

៥-កំណត់ហេតុសាកសួរឈ្មោះ [redacted] វណ្ណា។

៦-ពាក្យស្នើសុំបដិសេធលេខៈ ១០៨៦ ប.ជចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០។

៧-លិខិតស្នើសុំទប់ស្កាត់រក្សាការពារលេខៈ ១០៨៦ បជ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០។

**សំអាងហេតុ**

១-តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] សម្ផស្ស ភេទស្រី កើតឆ្នាំ១៩៨២ ឃើញថាធ្វើឡើងត្រឹមត្រូវស្របតាមទម្រង់ដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងទៀតឃើញថាទីតាំងនៃអចលនវត្ថុជាកម្មវត្ថុដែលសហដើមចោទបានប្តឹងសុំ គឺមានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ នាំឱ្យសាលាដំបូងខេត្តតាកែវអាចយករឿងនេះមកដោះស្រាយបានស្របតាមបញ្ញត្តិមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ផ្អែកតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ លេខក្បាលដី ៥៨៥ មានទំហំ ៨៧ម៉ែត្រការ៉េ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តតាកែវ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងវាំពក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ឃើញថាៈ មានឈ្មោះកម្មសិទ្ធិករ [redacted] វណ្ណា កើតឆ្នាំ១៩៦១ (ជាប្រពន្ធ [redacted] សីហា កើតឆ្នាំ១៩៥៤) មានទីលំនៅ [redacted] (ទ្រព្យខាងប្រពន្ធ)។ តាមរយៈវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើនេះអាចឱ្យតុលាការជឿជាក់បានថាពិតជាមានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] វណ្ណា (ជាប្រពន្ធ [redacted] សុីហា) (ទ្រព្យខាងប្រពន្ធ) ប្រាកដមែន។



Scanned with CamScanner

៣-ផ្អែកតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខៈ ៣៤៨ ប.ជ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ឃើញថាៈ មានឈ្មោះ [redacted] វណ្ណា ភេទស្រី កើតឆ្នាំ១៩៦១ បានផ្ទេរនូវដីលំនៅដ្ឋានដែលមានទំហំ ៨៧ ម៉ែត្រការ៉េ មានលេខក្បាលដីៈ ៥៨៨ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងវិពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ឱ្យទៅឈ្មោះ [redacted] សម្ផស្ស ភេទស្រី កើតថ្ងៃទី២១ ខែមករា ឆ្នាំ១៩៨៣ ដោយមានការផ្តិតស្នាមម្រាមដៃរបស់អ្នកផ្ទេរសិទ្ធិ អ្នកទទួលសិទ្ធិ និងមានសាក្សីដឹងឮ ព្រមទាំងមានចុះហត្ថលេខាដឹងឮពីសំណាក់មេភូមិ និងមេឃុំប្រាកដមែន។

៤-ផ្អែកតាមការអះអាងរបស់ដើមចោទឈ្មោះ [redacted] សម្ផស្ស ថាចំពោះដីដែលមានទំនាស់នេះ គឺដើមកំណើតដំបូងឡើយជាដីកម្មសិទ្ធិរបស់យាយខ្លួនឈ្មោះ [redacted] រ៉ន ដែលខ្លួនបានរស់នៅជាមួយគាត់តាំងពីតូចមក ហើយមុនពេលដែលយាយខ្លួនស្លាប់ទៅគាត់បានផ្តាំថាដីខាងលើនេះ គឺចែកទុកឱ្យខ្លួនដែលត្រូវជាចៅបង្កើត។ ក្រោយមកនៅក្នុងឆ្នាំ២០១៧ ខាងអាជ្ញាធរដែនដីបានចុះធ្វើការវាស់វែងដីដើម្បីចែកជូនប្រជាពលរដ្ឋជាលក្ខណៈប្រព័ន្ធនៅស្រុកត្រាំកក់ ខេត្តតាកែវ ហើយខ្លួនក៏បានឱ្យម្តាយខ្លួនឈ្មោះ [redacted] វណ្ណា មកធ្វើការចុះបញ្ជីដីនោះជាមួយនឹងខាងមន្ត្រីសុរិយោដីនៅខេត្តតាកែវជំនួសខ្លួន ដោយនៅពេលនោះខ្លួននៅជាប់រកស៊ីនៅខេត្តឧត្តមានជ័យ។ ក្រោយពេលមន្ទីរចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ ដាក់ឈ្មោះម្តាយខ្លួនរួចហើយ ម្តាយខ្លួនឈ្មោះ [redacted] វណ្ណា ក៏បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខៈ ៣៤៨ ប.ជ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ផ្ទេរដីខាងលើនេះឱ្យមកខ្លួនវិញ។ ក្នុងករណីនេះតុលាការយល់ឃើញថាៈ ប្រសិនបើទ្រព្យនោះជាកម្មសិទ្ធិរបស់យាយឈ្មោះ [redacted] រ៉ន ពិតមែនក៏ដោយ ហើយផ្អែកតាមការអះអាងរបស់ដើមចោទថាទ្រព្យសម្បត្តិខាងលើនេះជាទ្រព្យរបស់យាយខ្លួនឈ្មោះ [redacted] រ៉ន ទុកឱ្យខ្លួន គឺការអះអាងនេះគ្រាន់តែជាការអះអាងដោយផ្ទាល់មាត់របស់ខ្លួនតែប៉ុណ្ណោះ ដោយដើមចោទពុំមានឯកសារបញ្ជាក់ណាមួយតាមផ្លូវច្បាប់បញ្ជាក់អំពីការធ្វើអំណោយ ឬប្រទានកម្មពីយាយរបស់ខ្លួនឈ្មោះ [redacted] រ៉ន ឱ្យមកខ្លួននោះទេ។ មួយវិញទៀតក្នុងករណីមតកជនឈ្មោះ [redacted] រ៉ន ទទួលមរណភាពនោះទ្រព្យនោះនឹងត្រូវបានទៅលើចុងចម្លើយឈ្មោះ [redacted] វណ្ណា ដែលត្រូវជាកូនបង្កើត និងជាសន្តតិជនដែលមានលំដាប់ទី១ តាមបញ្ញត្តិមាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី ដែលជាអ្នកត្រូវទទួលបន្ត ពោល គឺមិនមែនត្រូវធ្លាក់ទៅលើចៅឈ្មោះ [redacted] សម្ផស្ស នោះទេ។

៥-ដោយឡែកទាក់ទងនឹងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខៈ ៣៤៨ ប.ជ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ដែលចុងចម្លើយឈ្មោះ [redacted] វណ្ណា បានធ្វើការផ្ទេរសិទ្ធិនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ២១០៩១៣០៣-០៥៨៥ នៃក្បាលដីលេខៈ ៥៨៨ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងវិពាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ឱ្យទៅដើមចោទឈ្មោះ [redacted] សម្ផស្ស ពិតមែន ក៏ប៉ុន្តែតុលាការយល់ឃើញថាៈ ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីខាងលើនេះ គឺគ្រាន់តែជាការផ្ទេរការគ្រប់គ្រងកាន់កាប់លើអចលនវត្ថុឱ្យទៅដើមចោទតែប៉ុណ្ណោះ ដោយមិនមែនជាការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុនោះឱ្យទៅដើមចោទជាម្ចាស់កម្មសិទ្ធិករនោះឡើយ។ ដោយយោងតាមសំអាងហេតុទាំងអស់ខាងលើនេះ គប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។

៦-យល់ឃើញថាៈ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តីតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

**ហេតុដូច្នេះសម្រេច**

១-ច្រានចោលការទាមទាររបស់ភាគីដើមចោទឈ្មោះ [redacted] សម្គស្ស ភេទស្រី កើតឆ្នាំ១៩៨៣ តាមពាក្យបណ្ដឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៃសំណុំរឿងរដ្ឋប្បវេណីលេខៈ ២៨៧ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ ។

-សាលក្រមនេះបានទាញហេតុផលផ្ទាល់មាត់ជសាធារណៈនាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ និងប្រកាសនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងចុងចម្លើយ។

-ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

តាកែវ,ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

តាកែវ, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**ចៅក្រម**

[redacted]



Scanned with CamScanner